ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ : ០៧៣ ឧ.រ.ថ.ផបវ.ប្រក

# ប្រកាស
## ស្តីពី
## សមមូលនៃប្រព័ន្ធឯកតាទម្ងន់ ផ្នែកលោហធាតុមានតម្លៃ

## រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី មាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានឃើញប្រកាសលេខ ៨៥៨ ឧរថ.បល.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
- ពិនិត្យតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-** ប្រកាសនេះមានគោលដៅកំណត់យន្តការ និងវិធានគ្រប់គ្រងលើការប្រើប្រាស់ប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃច្បាប់ស្តីពី មាត្រាសាស្ត្រកម្ពុជា និងការប្រើប្រាស់ប្រព័ន្ធឯកតា ក្រៅពីប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ចំពោះលោហធាតុមានតម្លៃ ។/

**ប្រការ ២.-** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលធ្វើពាណិជ្ជកម្ម ផលិតកម្ម សេវាកម្ម ពាក់ព័ន្ធនឹងលោហធាតុមានតម្លៃ (មាស ប្រាក់ ប្លាទីន ។ល។) ត្រូវតែគោរព និងប្រើប្រាស់ប្រព័ន្ធឯកតាមាត្រាសាស្ត្រ

ជាតិស្របច្បាប់ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃច្បាប់ ស្តីពីមាត្រាសាស្ត្រកម្ពុជា ។

ករណី រូបវន្តបុគ្គល ឬ នីតិបុគ្គលមានបំណងប្រើប្រាស់ប្រព័ន្ធឯកតាទម្ងន់ ផ្នែកលោហធាតុមានតម្លៃ ក្រៅពីប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ត្រូវស្នើសុំលិខិតអនុញ្ញាតពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**ប្រការ ៣.-** សមមូលលើឯកតាទម្ងន់ ផ្នែកលោហធាតុមានតម្លៃ មានដូចខាងក្រោមនេះ៖

| ល.រ | រាយនាមប្រព័ន្ធឯកតា | តម្លៃសមមូល |
|---|---|---|
| ១. | លី | ០,០៣៧៥ g (ក្រាម) |
| ២. | ហ៊ុន | ០,៣៧៥ g (ក្រាម) |
| ៣. | ជី | ៣,៧៥ g (ក្រាម) |
| ៤. | ដំឡឹង | ៣៧,៥ g (ក្រាម) |

**ប្រការ ៤.-** អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋាននីតិកម្ម មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ ៥.-** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រី**

**ស៊ុយ-សែម**

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ធនាគារជាតិនៃកម្ពុជា
- គ្រប់ក្រសួង - ស្ថាប័នជំនាញពាក់ព័ន្ធ
- សភាពាណិជ្ជកម្មកម្ពុជា
- គ្រប់សាលារាជធានី - ខេត្ត

"ដើម្បីជូនជ្រាប"

- គ្រប់នាយកដ្ឋានសេនាធិការ និងថ្នាក់ស្មើ នៃក្រសួងឧរថ
- គ្រប់សហគ្រាសសាធារណៈចំណុះក្រសួងឧរថ
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី - ខេត្ត

"ដើម្បីសហការអនុវត្ត"

- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ